ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី..០៦..ខែ..វិច្ឆិកា..ឆ្នាំ ២០១៣

លេខ:...៤១៦...វបសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ

—

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ០៥អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- តាមការចាំបាច់របស់ក្រសួងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

## សម្រេច

**ប្រការ១ ៖**

ត្រូវបានបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ ប្រធាន

-



ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម ផ្ទះ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

| | | | | |
|---|---|---|---|---|
| ២- ឯកឧត្តម | សោម | សុគន្ធ | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម | អ៊ុន | ធឹម | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម | ចំរើន | ម៉ាន់ថា | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម | ហាប់ | ទូច | អគ្គនាយកបេតិកភណ្ឌ | សមាជិក |
| ៦- ឯកឧត្តម | មុខ | សុចត្ថិ | សាកលវិទ្យាធិការ | សមាជិក |
| ៧- លោក | ឡុង | ប៉ុណ្ណាស៊ីរីវឌ្ឍ | អគ្គនាយកបច្ចេកទេសវប្បធម៌ | សមាជិក |
| ៨- លោក | ម៉ុន | ហៀង | នាយករងសាលាមធ្យម | សមាជិក |

**ប្រការ២ ៖**

ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយមានភារកិច្ចដូចខាងក្រោម៖

- អប់រំ ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយនៅក្នុងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- ធ្វើបញ្ជីសមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលដើម្បីផ្ញើជូនអង្គភាពប្រឆាំងអំពើពុករលួយ

- ជួយសម្រួលការងារប្រកាសទ្រព្យសម្បត្តិ និងបំណុលឲ្យដំណើរការបានត្រឹមត្រូវច្បាស់លាស់ និងទាន់ពេលវេលា

- ធ្វើជាសេនាធិការឲ្យលោកជំទាវរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក្នុងការកសាងផែនការសកម្មភាពបង្ការ និងទប់ស្កាត់អំពើពុករលួយដើម្បីកសាងអង្គភាពស្អាត

- ធ្វើរបាយការណ៍ អំពីលទ្ធផលការងារពាក់ព័ន្ធនឹងអំពើពុករលួយជូនអង្គភាពប្រឆាំងអំពើពុករលួយដោយមានការឯកភាពពី លោកជំទាវក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ៣ ៖**

- រាល់សេចក្តីសម្រេចទាំងឡាយណាផ្ទុយនឹងសេចក្តីសម្រេចនេះទុកជានិរាករណ៍ ។

**ប្រការ៤ ៖**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នាយកសាលាមធ្យមវិចិត្រសិល្បៈ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន៖**
- អង្គភាពប្រឆាំងអំពើពុករលួយ
«ដើម្បីជូនជ្រាប»
- ដូចប្រការ១ និងប្រការ៤
«ដើម្បីអនុវត្ត»។
ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

ភឿង_សកុណា